ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងសុខាភិបាល
Ministry of Health

# រូបមន្តស្តង់ដារព្យាបាលជំងឺរបេង
# Tuberculosis Standard Treatment Regimens

មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន
National Center for Tuberculosis and Leprosy Control

តុលា ២០១១

# មាតិកា


ទំព័រ

អារម្ភកថា ៣

ក) -ការធ្វើរោគវិនិច្ឆ័យជំងឺរបេង ៤

ខ) -រូបមន្តព្យាបាលជំងឺរបេងសំរាប់មនុស្សពេញវ័យ ៧

១.រូបមន្តប្រភេទទី ១ ៧

២.រូបមន្តព្យាបាលជំងឺរបេងស្រោមខួរ ឬរបេងមីលីយែរ ៩

៣.រូបមន្តប្រភេទទី ២ ១១

៤.រូបមន្តប្រភេទទី ៣ ១៣

គ) -រូបមន្តព្យាបាលជំងឺរបេងសំរាប់កុមារ ១៥

១.រូបមន្តប្រភេទទី ១ ១៥

២.រូបមន្តព្យាបាលជំងឺរបេងស្រោមខួរ ១៧

៣.រូបមន្តប្រភេទទី ២ ១៩

៤.រូបមន្តប្រភេទទី ៣ ២១

ឃ) -និយមន័យ ២៣

# អារម្ភកថា

ការកំណត់រោគវិនិច្ឆ័យជំងឺរបេងបានសមស្រប និងការប្រើប្រាស់រូបមន្តត្រឹមត្រូវ និងក្នុងរយៈពេលពេញលេញ នៃការព្យាបាលជំងឺរបេង រួមទាំងការអនុវត្តនីវិធីសាស្ត្រព្យាបាល ក្រោមការត្រួតពិនិត្យផ្ទាល់ដោយបុគ្គលិកសុខាភិបាល ឬអ្នកដែលបានទទួលការបណ្តុះបណ្តាល ហៅកាត់ថា " ដូតស៍ " មានសារៈសំខាន់ណាស់ដើម្បីអោយអ្នកជំងឺទទួលបានការជាសះស្បើយ ។

រូបមន្តស្តង់ដារនៃការព្យាបាលជំងឺរបេង នៅក្នុងកូនសៀវភៅនេះ បានរៀបចំ និងកែលំអឡើងដោយផ្អែកលើរូបមន្តណែនាំដោយអង្គការសុខភាពពិភពលោក (២០១០ និង ២០១១) និងលើកូនសៀវភៅកម្មវិធីជាតិដែលបានចេញផ្សាយនៅខែ មិនា ២០០៨ ។ ការកែលំអសំខាន់គឺពាក់ពន្ធ័នឹងកំរិតថ្នាំ និងរយៈពេលព្យាបាលសំរាប់ជំងឺរបេងកុមារ ។ កូនសៀវភៅនេះចែកចេញជាបីផ្នែក: ផ្នែកនៃការធ្វើរោគវិនិច្ឆ័យ ផ្នែកនៃរូបមន្តព្យាបាលជំងឺរបេងលើមនុស្សពេញវ័យ និងផ្នែកនៃរូបមន្ត ព្យាបាលជំងឺរបេងលើកុមារ ។

កូនសៀវភៅនេះរៀបចំឡើង សំរាប់បុគ្គលិកសុខាភិបាលដែលបំរើការងារប្រយុទ្ធនឹងជំងឺរបេងនៅគ្រប់លំដាប់ថ្នាក់ ។ សៀវភៅនេះក៏មានអត្ថប្រយោជន៏ផងដែរ សំរាប់បុគ្គលិកសុខាភិបាលផ្សេងៗទៀត និងអ្នកដទៃទៀតដែលមានការពាក់ពន្ធ័ និងចំណាប់អារម្មណ៍ ក្នុងការងារប្រយុទ្ធនឹង ជំងឺរបេង ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ តុលា ឆ្នាំ ២០១១

**អគ្គនាយកបច្ចេកទេសសុខាភិបាល**

**វេជ្ជ. ឆេព លន់**

# ក-ការធ្វើរោគវិនិច្ឆ័យជំងឺរបេង

ជំងឺរបេងចែកចេញជា  ជំងឺរបេងសួត និងជំងឺរបេងក្រៅសួត  ។

## ១.របេងសួត :

រោគសញ្ញាសំខាន់ហើយចំបង  នៃជំងឺរបេងសួតគឺ ក្អកជាប្រចាំលើសពី ២ ទៅ ៣សប្តាហ៍ ឡើងទៅ ជាទូទៅគឺក្អក  មានស្លេស ។ អ្នកដែលមានរោគសញ្ញាបែបនេះ ត្រូវតែធ្វើការពិនិត្យកំហាកឱ្យបាន ឆាប់រហ័សជាទីបំផុត ។

សញ្ញាក្អកលើសពី២-៣សប្តាហ៍  ដែលជាសញ្ញាចំបង  ជាទូទៅតែងរួមផ្សំជាមួយរោគសញ្ញាមួយឬច្រើន ដូចជា: ស្រកទំងន់ អស់កំលាំង គ្រុនក្តៅ ស្រៀវស្រាញពេលល្ងាច បែកញើសនៅពេលយប់ ឈឺទ្រូង ហត់ បាយមិនឆ្ងាញ់ ក្អកធ្លាក់ឈាម ជាដើម ។

### ក-របេងសួតវិជ្ជមានបេកា :

- វិជ្ជមានបេកាយ៉ាងតិច ២ ដងតាមរយៈការពិនិត្យកំហាកដោយមីក្រូទស្សន៍ ឬ
- វិជ្ជមានបេកា ១ ដង រួមផ្សំនឹងសញ្ញារូបថតសួតគួរឱ្យចាប់អារម្មណ៍ថាមានរបេងសកម្ម ឬ
- វិជ្ជមានបេកា ១ ដង រួមផ្សំនឹងការបណ្តុះមេរោគឃើញមានបេកាវិជ្ជមាន ។

### ខ-របេងសួតអវិជ្ជមានបេកា :

- អវិជ្ជមានបេកាយ៉ាងតិច ៦ ដង រួមផ្សំនឹងសញ្ញារូបថតសួតគួរឱ្យចាប់អារម្មណ៍ថាមានរបេងសកម្ម ។

## ២.របេងក្រៅសួត :

រោគវិនិច្ឆ័យជាក់លាក់របស់ជំងឺរបេងក្រៅសួត មានការពិបាកនឹងកំណត់  និងអាស្រ័យទៅតាមវត្តមាន  នៃឧបករណ៍ធ្វើរោគវិនិច្ឆ័យ  ដែលមានដូចជា ការច្រិបយកជាលិកា និងការពិនិត្យជាលិកាសាស្ត្រជាដើម ។

ទ្រង់ទ្រាយនៃជំងឺរបេងក្រៅសួត  ដែលសង្កេតឃើញជាញឹកញាប់រួមមាន:  របេងកូនកណ្តុរ,  របេងស្រោមសួត, របេងស្រោមបេះដូង, របេងស្រោមខួរ, របេងឆ្អឹង, របេងមីលីយែរ  ។ល។

អ្នកដែលមានជំងឺរបេងក្រៅសួត  ក៏អាចមានរោគសញ្ញាទូទៅប្រហាក់ប្រហែលនឹងជំងឺរបេងសួតផងដែរ: ស្រក់ទំងន់, គ្រុនក្តៅ ស្រៀវស្រាញនៅពេលល្ងាច, បែកញើសនៅពេលយប់ ។

រោគសញ្ញាផ្សេងទៀតកើតឡើង អាស្រ័យសរីរាង្គដែលទទួលរងជំងឺ  ឧទាហរណ៍ដូចជា :

- ហើមប៉ោងដូនកាលមានហៀរខ្ទុះ កាលណាមានរបេងកូនកណ្តុរ ។
- ហើមប៉ោង ហើយដូនកាលឈឺចាប់  កាលណាមានរបេងសន្លាក់ឆ្អឹង ។
- ឈឺក្បាល  គ្រុនក្តៅ  រឹងក និងភាពសន្លឹម កាលណាមានរបេងស្រោមខួរ ( ជាពិសេសចំពោះកុមារ ) ។

ប្រសិនសង្ស័យថាជារបេងក្រៅសួតនោះ ត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យបង្អែក ដើម្បីឱ្យគ្រូពេទ្យ ធ្វើរោគវិនិច្ឆ័យ ។ ចំពោះអ្នកមានរបេងក្រៅសួត គេក៏ត្រូវស្រាវជ្រាវរកផងដែរនូវ ជំងឺរបេងសួត ពិសេសតាមរយៈការពិនិត្យកំហាក និងការថតសួត បើសិនជាអ្នកជំងឺមានក្អក និងមានស្លេស ។

**៣-របេងកុមារ :** ពឹងផ្អែកលើ :

**-ការសាកសួរប្រវត្តិ** (ប្រវត្តិនៃការរស់នៅជិតស្និទ្ធជាមួយនឹងអ្នកជំងឺរបេង និងរោគសញ្ញាជំងឺ)

- អ្នកនៅជិតស្និទ្ធ ជាមួយអ្នកជំងឺរបេង ហើយដែលមានរោគសញ្ញា : គឺជាអ្នករស់នៅក្នុងផ្ទះតែមួយ ឬអ្នកដែលមានទំនាក់ទំនងជាញឹកញាប់ជាមួយនឹងអ្នកជំងឺរបេងសួតវិជ្ជមានបេកា (ឧទាហរណ៍ អ្នកថែរក្សាទារក ឬកុមារ) ។

រោគសញ្ញា : ក្អករ៉ាំរ៉ៃ គ្រុនក្តៅ ស្រកទំងន់ ឬមិនឡើងទំងន់ ។

**-ការពិនិត្យគ្លីនិក (ការវាយតម្លៃ)**

- សញ្ញាគ្លីនិកជំរុញយ៉ាងខ្លាំងឱ្យគិតដល់ជំងឺរបេងក្រៅសួត :

  -គមខ្នង ជាពិសេស ទើបកើតមានថ្មី (ជាលទ្ធផលនៃជំងឺរបេងឆ្អឹងខ្នង)

  -ឡើងកូនកណ្តុរត្រង់ក រីកធំគ្មានការឈឺចាប់ ដែលមានហូរទឹករងៃ ។

- រោគសញ្ញាគ្លីនិកទាមទារការស្រាវជ្រាវ ដើម្បីផាត់ចោលជំងឺរបេងក្រៅសួត : ជំងឺរលាកស្រោមខួរ រលាកស្រោមសួត រលាកស្រោមបេះដូង ប៉ោងពោះធំដោយមានទៀចទឹក ឡើងកូនកណ្តុររីកធំដោយ គ្មានការឈឺចាប់ដោយគ្មានហូរទឹករងៃ ហើមសន្លាក់ដោយគ្មានការឈឺចាប់ និងសញ្ញាឆ្លើយតបទៅនឹងតេស្តទុយបែគុយលីន ។

**-ការធ្វើតេស្តទុយប៊ែរគុយលីន :**

តេស្តទុយប៊ែរគុយលីនវិជ្ជមាន កើតឡើងនៅពេលដែលមនុស្សម្នាក់បានឆ្លងមេរោគរបេង ប៉ុន្តែមិនបញ្ជាក់អំពីជំងឺរបេងសកម្មទេ ។ គេធ្វើតេស្តទុយប៊ែរគុយលីន សម្រាប់ជាសមាសភាគរួមគ្នាក្នុងការធ្វើរោគ វិនិច្ឆ័យជំងឺរបេងកុមារដោយភ្ជាប់ជាមួយនឹងការធ្វើតេស្តរោគវិនិច្ឆ័យដ៏ទៃទៀត ។

តេស្តទុយប៊ែរគុយលីនត្រូវបានចាត់ទុកថាវិជ្ជមាន ក្នុងករណីដូចខាងក្រោមនេះ :

- ចំពោះកុមារប្រឈមនឹងគ្រោះថ្នាក់ (កុមារឆ្លងមេរោគអេដស៍ និងកុមារដែលខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ): ប្រតិកម្មកន្ទួលលើស្បែកមានវិជ្ជមាត្រធំជាង ៥ មីលីម៉ែត្រ ។

- គ្រប់កុមារដ៏ទៃទៀត (បានទទួលថ្នាំបង្ការបេសេហ្សេ ឬគ្មាន ): ប្រតិកម្មកន្ទួលលើស្បែកមានវិជ្ជមាត្រ ស្មើឬធំជាង ១០ មីលីម៉ែត្រ ។

**-ការអះអាងបាក់តេរីសាស្ត្រ ក្នុងករណីដែលអាចធ្វើបាន :**

សំណាកគំរូជំសមស្របពីកន្លែងដែលសង្ស័យថាអាចមានការពាក់ព័ន្ធ (កំហាក ទឹកលាងក្រពះ ជាលិកាកូនកណ្ដុរ និងកន្លែងផ្សេងទៀតដែលអាចច្រិបយកមកវិភាគ ) ត្រូវតែបានទទួលការពិនិត្យដោយមីក្រូទស្សន៍ និងចំពោះកន្លែងដែលមានលទ្ធភាព គេគប្បីធ្វើការបណ្ដុះមេរោគ និងពិនិត្យជាលិកា រោគសាស្ត្រ ។

**-ការស្រាវជ្រាវពាក់ព័ន្ធនឹងករណីសង្ស័យជំងឺរបេងសួត និងក្រៅសួត :**

- ករណីសង្ស័យរបេងសួត : ការថតសួត : opacification, miliaire, infiltrates.
- ករណីសង្ស័យរបេងក្រៅសួត :

-របេងកូនកណ្ដុរ : ច្រិបជាលិកាកូនកណ្ដុរ ឬចោះបឺតដោយម្ជុលតូច ។

-របេងមីលីយែរ : ថតសួត និងបូមទឹកឆ្អឹងខ្នង ។

-របេងស្រោមខួរ : បូមទឹកឆ្អឹងខ្នង និងស្កាន់ន័រ បើសិនជាមាន ។

-របេងស្រោមសួត : ថតសួត បូមទឹកស្រោមសួត ។

-របេងក្នុងពោះ : អេកូសាស្ត្រពោះ និងបូមទឹកស្រោមពោះ ។

-របេងឆ្អឹង : ថតឆ្អឹង បូមទឹកសន្លាក់ ឬច្រិបជាលិកាសន្លាក់ ។

-របេងស្រោមបេះដូង : អេកូសាស្ត្របេះដូង និងបូមទឹកស្រោមបេះដូង ។

**-តេស្តរកមេរោគអេដស៍ :**

គ្រប់កុមារសង្ស័យថាមានជំងឺរបេង ត្រូវផ្ដល់អនុសាសន៍ក្នុងការធ្វើតេស្តរកមេរោគអេដស៍ ។

**ក្នុងករណីសំណាកគំរូពុំអាចយកបាន ឬលទ្ធផលពិនិត្យរកមេរោគអវិជ្ជមាន ពុំមានលទ្ធផល វត្តមានចំណុចខាងក្រោមបី ឬ ច្រើន ផ្ដល់យោបល់លើការធ្វើរោគវិនិច្ឆ័យជំងឺរបេងកុមារ :**

-រោគសញ្ញារ៉ាំរ៉ៃដែលជំរុញឱ្យគិតដល់ជំងឺរបេង

-រោគសញ្ញាគ្លីនិកដែលជំរុញយ៉ាងខ្លាំងឱ្យគិតដល់ជំងឺរបេង

-តេស្តទុយប៊ែរគុយលីនលើស្បែកវិជ្ជមាន ឬរស់នៅជិតស្និទ្ធជាមួយអ្នកជំងឺរបេងវិជ្ជមានបេកា ទើបធ្វើរោគវិនិច្ឆ័យថ្មីៗ

-រូបភាពនៃការថតសួតជំរុញឱ្យគិតដល់ជំងឺរបេង ។

## ខ. រូបមន្តព្យាបាលជំងឺរបេងសំរាប់មនុស្សពេញវ័យ

រូបមន្តស្តង់ដារព្យាបាលជំងឺរបេងសំរាប់មនុស្សពេញវ័យ ក្នុងព្រះរាជាណាចក្រកម្ពុជាមាន ៣ ប្រភេទ ។ រូបមន្តនីមួយៗ មានរយៈពេលសរុបពី ៦ ទៅ ៨ ខែ និងចែកចេញជាពីរដំណាក់កាល គឺដំណាក់កាលព្យាបាលដំបូង (ឬព្យាបាលសំរុក) និងដំណាក់កាលព្យាបាលបន្ត ។

### រូបមន្តប្រភេទទី ១ : 2RHZE / 4RH

រូបមន្តប្រភេទទី ១ នេះ គឺសំរាប់ព្យាបាលអ្នកជំងឺរបេងករណីថ្មីនៃ :

- ជំងឺរបេងសួតវិជ្ជមានបេកា
- ជំងឺរបេងសួតអវិជ្ជមានបេកាធ្ងន់ធ្ងរ ( មានដំបៅសួតរាលដាល )
- ជំងឺរបេងក្រៅសួតធ្ងន់ធ្ងរ ( ស្រោមបេះដូង, ស្រោមពោះ, ស្រោមសួតទាំងសងខាង ឬធ្ងន់ធ្ងរ, ឆ្អឹងខ្នង, ពោះវៀន, ប្រដាប់បន្តពូជ-តម្រងនោម )
- ជំងឺរបេង/អេដស៍

*** ដំណាក់កាលព្យាបាលដំបូង:** មានរយៈពេល ២ ខែ (1)

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ៤ មុខ ជារៀងរាល់ព្រឹក រយៈពេល ២ ខែ នៅចំពោះមុខបុគ្គលិកសុខាភិបាល ឬចំពោះមុខអ្នកដែលបានបណ្តុះបណ្តាល (ហៅថា ដូតស៍) ។ ថ្នាំទាំង ៤ មុខនោះ គឺ ថ្នាំរីហ្វាំពីស៊ីន ថ្នាំអ៊ីសូនីយ៉ាស៊ីដ ថ្នាំពីរ៉ាស៊ីណាមីដ និងថ្នាំអេតំប៊ុយតុល ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់) ។

(1) *នៅចុងខែទី ២ នៃការព្យាបាល ក្នុងករណីដែល ការពិនិត្យកំហាក ឃើញនៅតែវិជ្ជមានបេកា នោះត្រូវបន្តការព្យាបាលវគ្គដំបូង ១ ខែទៀត ។ ចំពោះករណីនេះ ដំណាក់កាលព្យាបាលបន្តនៅតែ ៤ ខែដដែល ហើយរយៈពេលនៃការព្យាបាលសរុបគឺ ៧ ខែ ។*

*** ដំណាក់កាលព្យាបាលបន្ត:** មានរយៈពេល ៤ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ២ មុខ ជារៀងរាល់ព្រឹកគ្រប់រយៈពេល ៤ ខែ ក្រោមការពិនិត្យផ្ទាល់ របស់សមាជិកសហគមន៍ ដែលបានទទួលការណែនាំពី បុគ្គលិកសុខាភិបាល ។
ថ្នាំទាំង ២ មុខនោះ គឺថ្នាំ រីហ្វាំពីស៊ីន និងអ៊ីសូនីញ៉ាស៊ីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) ។
ចំពោះកំរិតថ្នាំ ឬចំនួនគ្រាប់ថ្នាំដែលត្រូវប្រើ សូមអានតារាងនៅទំព័របន្ទាប់ ។

## រូបមន្តប្រភេទទី ១ : 2RHZE / 4RH

| ដំណាក់កាលព្យាបាលដំបូង<br>លេបរាល់ថ្ងៃក្រោមការត្រួតពិនិត្យផ្ទាល់ ( ដូតស៍ ) រយៈពេល ២ ខែ | | ដំណាក់កាលព្យាបាលបន្ត<br>លេបរាល់ថ្ងៃរយៈពេល ៤ ខែ |
|---|---|---|
| ទម្ងន់មុនពេលព្យាបាល | RHZE<br>150/75/400/275 ម.ក្រ | RH<br>150/75 ម.ក្រ |
| 30-39 គ.ក្រ | 2 ( គ្រាប់) | 2 ( គ្រាប់) |
| 40-54 គ.ក្រ | 3 ( គ្រាប់) | 3 ( គ្រាប់) |
| 55-70 គ.ក្រ | 4 ( គ្រាប់) | 4 ( គ្រាប់) |
| > 70 គ.ក្រ | 5 ( គ្រាប់) | 5 ( គ្រាប់) |
| កំរិតថ្នាំគ.ក្រ / ថ្ងៃ | R= 10 ម.ក្រ, H = 5 ម.ក្រ, Z = 25 ម.ក្រ, E = 15 ម.ក្រ | |

RHZE: រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ + ពីរ៉ាស៊ីណាមីដ + អេតំប៊ុយតុល RH: រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ.

ម.ក្រ : មីលីក្រាម, គ.ក្រ : គីឡូក្រាម

# រូបមន្តប្រភេទទី១:

## រូបមន្តព្យាបាលមនុស្សពេញវ័យដែលមានជំងឺរបេងស្រោមខួរ ឬរបេងមីលីយែរ :

## 2RHZS (1) / 4RH

នៅក្នុងរូបមន្តនេះ គេប្រើថ្នាំស្ត្រិបតូមីស៊ីនជំនួសថ្នាំអេតាំប៊ុតុល ព្រោះថ្នាំស្ត្រិបតូមីស៊ីនអាចជ្រាបចូលក្នុងស្រោមខួរក្បាលបានល្អ ។

*** ដំណាក់កាលព្យាបាលដំបូង:** មានរយៈពេល ២ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេប និងចាក់ថ្នាំ ៥ មុខ ជារៀងរាល់ព្រឹក រយៈពេល ២ ខែ នៅចំពោះមុខបុគ្គលិកសុខាភិបាល ឬចំពោះមុខអ្នកដែលបានបណ្តុះបណ្តាល ( ហៅថា ដូតស៍) ។

ថ្នាំទាំង ៥ មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន ថ្នាំអ៊ីសូនីយ៉ាស៊ីដ ថ្នាំពីរ៉ាស៊ីណាមីដ និងថ្នាំអេតំប៊ុយតុល ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់) និងថ្នាំស្ត្រិបតូមីស៊ីន។

*** ដំណាក់កាលព្យាបាលបន្ត:** មានរយៈពេល ៤ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ២ មុខ ជារៀងរាល់ព្រឹកគ្រប់រយៈពេល ៤ ខែ។

ថ្នាំទាំង ២ មុខនោះ គឺថ្នាំ រីហ្វាំពីស៊ីន និងអ៊ីសូនីយ៉ាស៊ីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់) ។

ចំពោះកំរិតថ្នាំ ឬចំនួនគ្រាប់ថ្នាំដែលត្រូវប្រើ សូមអានតារាងនៅទំព័របន្ទាប់ ។

(1) ក្នុងករណីមិនមានថ្នាំ RHZ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) គេអាចប្រើ RHZE ជំនួស ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) រួមជាមួយនឹងថ្នាំចាក់ស្ត្រិបតូមីស៊ីន ។

## រូបមន្តប្រភេទទី១:

### រូបមន្តព្យាបាលមនុស្សពេញវ័យដែលមានជំងឺរបេងស្រោមខួរ ឬរបេងមីលីយែរ : 2RHZS / 4RH

| ដំណាក់កាលព្យាបាលដំបូង<br>លេប និងចាក់រាល់ថ្ងៃក្រោមការត្រួតពិនិត្យផ្ទាល់ ( ដូតស៍ ) រយៈពេល ២ ខែ | | | ដំណាក់កាលព្យាបាលបន្ត<br>លេបរាល់ថ្ងៃរយៈពេល ៤ ខែ |
|---|---|---|---|
| ទម្ងន់មុនពេលព្យាបាល | RHZ★<br>150/75/400 ម.ក្រ | S<br>1000ម.ក្រ | RH<br>150/75 ម.ក្រ |
| 30-39 គ.ក្រ | 2 ( គ្រាប់) | 500 | 2 ( គ្រាប់) |
| 40-54 គ.ក្រ | 3 ( គ្រាប់) | 750 | 3 ( គ្រាប់) |
| 55-70 គ.ក្រ | 4 ( គ្រាប់) | 1000 | 4 ( គ្រាប់) |
| > 70 គ.ក្រ | 5 ( គ្រាប់) | 1000 | 5 ( គ្រាប់) |
| កំរិតថ្នាំគ.ក្រ/១ថ្ងៃ | R = 10ម.ក្រ, H = 5ម.ក្រ, Z = 25ម.ក្រ, E =15 ម.ក្រ, S =15 ម.ក្រ | | |

RHZ : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ + ពីរ៉ាស៊ីណាមីដ , S : ស្ត្រិបតូមីស៊ីន, RH : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ,

ម.ក្រ : មីលីក្រាម, គ.ក្រ : គីឡូក្រាម

★ក្នុងករណីពុំមាន RHZ គេអាចប្រើ RHZE ជំនួស

## របមន្តប្រភេទទី ២ : 2RHZES / 1RHZE / 5RHE

របមន្តប្រភេទទី ២ នេះ មានរយៈពេលសរុប ៨ ខែ និងសំរាប់ព្យាបាលជំងឺរបេងដូចខាងក្រោមៈ

- ករណីរបេងលាប់
- ករណីរបេងបរាជ័យ
- ករណីរបេងត្រឡប់មកវិញក្រោយបោះបង់ការព្យាបាល
- ករណីផ្សេងៗ

*** ដំណាក់កាលព្យាបាលដំបូងៈ** មានរយៈពេល ៣ ខែ (1) ដោយចែកចេញជាពីរផ្នែកទៀត :

- ផ្នែកទី ១: មានរយៈពេល ២ ខែ ដោយប្រើថ្នាំ ៥ មុខ ។ នៅក្នុងរយៈពេល ២ ខែនេះ អ្នកជំងឺត្រូវលេប និង ចាក់ថ្នាំ ជារៀងរាល់ព្រឹក នៅចំពោះមុខបុគ្គលិកសុខាភិបាល ។ ថ្នាំទាំង៥មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន ថ្នាំអ៊ីសូនីយ៉ាស៊ីដ ថ្នាំពីរ៉ាស៊ីណាមីដ និងថ្នាំអេតំប៊ុយតុល ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) និងថ្នាំស្ត្រើបតូម៉ីស៊ីន ។
- ផ្នែកទី២: មានរយៈពេល ១ ខែ ដោយប្រើថ្នាំ ៤ មុខ ។ នៅក្នុងរយៈពេល ១ ខែនេះ អ្នកជំងឺត្រូវលេបថ្នាំ ជារៀងរាល់ព្រឹក នៅចំពោះមុខបុគ្គលិកសុខាភិបាល ឬចំពោះមុខអ្នកដែលបានបណ្តុះបណ្តាល ។ ថ្នាំទាំង ៤ មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន ថ្នាំអ៊ីសូនីយ៉ាស៊ីដ ថ្នាំពីរ៉ាស៊ីណាមីដ និងថ្នាំអេតំប៊ុយតុល ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) ។

(1) *ក្នុងករណី នៅចុងខែទី ៣ នៃការព្យាបាល ការពិនិត្យកំហាកឃើញនៅតែវិជ្ជមានបេកា នោះត្រូវបន្តការព្យាបាលវគ្គដំបូង ១ ខែទៀត ( ផ្នែកទី២ ) ។ ចំពោះករណីនេះ ដំណាក់កាលព្យាបាលបន្ត នៅសល់តែ ៤ ខែប៉ុណ្ណោះ ។*

*** ដំណាក់កាលព្យាបាលបន្តៈ** មានរយៈពេល ៥ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ៣ មុខ ជារៀងរាល់ព្រឹក នៅចំពោះមុខ សមាជិកសហគមន៍ដែលបានទទួលការណែនាំ។ ការផ្តល់ថ្នាំដល់អ្នកជំងឺ ត្រូវធ្វើឡើងយ៉ាងតិចរាល់ពីរអាទិត្យ ជាមួយនឹងដំបូន្មានទៀងទាត់របស់បុគ្គលិកសុខាភិបាល ។ ថ្នាំទាំង៣មុខនោះគឺ ថ្នាំរីហ្វាំពីស៊ីន និងអ៊ីសូនីយ៉ាស៊ីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) និងថ្នាំអេតំប៊ុយតុល ។

ចំពោះកំរិតថ្នាំ ឬចំនួនគ្រាប់ថ្នាំដែលត្រូវប្រើ សូមអានតារាងនៅទំព័របន្ទាប់ ។

## រូបមន្តប្រភេទទី ២ : 2RHZES / 1RHZE / 5RHE

| ដំណាក់កាលព្យាបាលដំបូង<br>លេបនិងចាក់រាល់ថ្ងៃក្រោមការត្រួតពិនិត្យផ្ទាល់ ( ដូតស៍ ) | | | | ដំណាក់កាលបន្ត<br>លេបរាល់ថ្ងៃ | |
|---|---|---|---|---|---|
| ខែទី ១ និងខែទី ២ | | | ខែទី ៣ | ខែទី ៤ ដល់ខែទី ៨ | |
| ទម្ងន់មុន ព្យាបាល | RHZE<br>150/75/400/275 ម.ក្រ | S<br>1000 ម.ក្រ | RHZE<br>150/75/400/275 ម.ក្រ | RH<br>150/75 ម.ក្រ | E<br>400 ម.ក្រ |
| 30-39 គ.ក្រ | 2 ( គ្រាប់) | 500 ម.ក្រ | 2 ( គ្រាប់) | 2 ( គ្រាប់) | 1.5 ( គ្រាប់) |
| 40-54 គ.ក្រ | 3 ( គ្រាប់) | 750 ម.ក្រ | 3 ( គ្រាប់) | 3 ( គ្រាប់) | 2 ( គ្រាប់) |
| 55-70គ.ក្រ | 4 ( គ្រាប់) | 1000 ម.ក្រ | 4 ( គ្រាប់) | 4 ( គ្រាប់) | 3 ( គ្រាប់) |
| >70 គក | 5 ( គ្រាប់) | 1000 ម.ក្រ | 5 ( គ្រាប់) | 5 ( គ្រាប់) | 3.5 ( គ្រាប់) |
| កំរិតថ្នាំគ.ក្រ / ១ថ្ងៃ | R = 10ម.ក្រ, H = 5ម.ក្រ, Z = 25ម.ក្រ, E = 15ម.ក្រ, S = 15ម.ក្រ | | | | |

ចំណាំ RHZE : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ + ពីរ៉ាស៊ីណាមីដ + អេតំប៊ុយតុល, S : ស្ត្រិបតូមីស៊ីន, RH : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ, E : អេតំប៊ុយតុល

S : ស្ត្រិបតូមីស៊ីន : -ចំពោះអ្នកជំងឺអាយុលើស ៤៥ ឆ្នាំ ត្រូវប្រើស្ត្រិបតូមីស៊ីនតែ ៧៥០ម.ក្រ/១ថ្ងៃ

-ហាមប្រើចំពោះស្ត្រីមានផ្ទៃពោះ ។ ម.ក្រ : មីលីក្រាម, គ.ក្រ : គីឡូក្រាម

## រូបមន្តប្រភេទទី ៣ : 2RHZE / 4RH

រូបមន្តប្រភេទទី ៣ នេះ គឺសំរាប់ព្យាបាលអ្នកជំងឺរបេងករណីថ្មីដូចខាងក្រោម៖

-ជំងឺរបេងសួតអវិជ្ជមានបេកា សណ្ឋានមិនធ្ងន់ធ្ងរ (ដំបៅសួតមិនរាលដាល)

-ជំងឺរបេងក្រៅសួត សណ្ឋានមិនធ្ងន់ធ្ងរ (កូនកណ្តុរ, ស្រោមសួតតែម្ខាង, ឆ្អឹង លើកលែងឆ្អឹងខ្នង, សន្លាក់ខាងក្រៅ, ក្រពេញអាដ្រេណាល់)

*** ដំណាក់កាលព្យាបាលដំបូង:** មានរយៈពេល ២ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ៤ មុខ ជារៀងរាល់ព្រឹក រយៈពេល ២ ខែ នៅចំពោះមុខបុគ្គលិកសុខាភិបាល ឬចំពោះមុខអ្នកដែលបានបណ្តុះបណ្តាល ។

ថ្នាំទាំង ៤ មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន ថ្នាំអ៊ីសូនីយ៉ាស៊ីដ ថ្នាំពីរ៉ាស៊ីណាមីដ និងថ្នាំអេតំប៊ុយតុល (ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់) ។

*** ដំណាក់កាលព្យាបាលបន្ត:** មានរយៈពេល ៤ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ២ មុខជារៀងរាល់ព្រឹក គ្រប់រយៈពេល ៤ ខែ ។

ថ្នាំទាំង ២ មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន និងអ៊ីសូនីយ៉ាស៊ីដ (ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់) ។

ចំពោះកំរិតថ្នាំឬចំនួនគ្រាប់ថ្នាំដែលត្រូវប្រើ សូមអាននៅទំព័របន្ទាប់ ។

## រូបមន្តប្រភេទទី៣ : 2RHZE / 4RH

| | ដំណាក់កាលដំបូង<br>លេបរាល់ថ្ងៃក្រោមការ ត្រួតពិនិត្យផ្ទាល់រយៈពេល ២ ខែ | ដំណាក់កាលបន្ត<br>លេបរាល់ថ្ងៃរយៈពេល ៤ ខែ |
|---|---|---|
| ទម្ងន់មុនពេលព្យាបាល | RHZE<br>150/75/400/275 ម.ក្រ | RH<br>150/75 ម.ក្រ |
| 30-39 គ.ក្រ | 2 ( គ្រាប់) | 2 ( គ្រាប់) |
| 40-54 គ.ក្រ | 3 ( គ្រាប់) | 3 ( គ្រាប់) |
| 55-70 គ.ក្រ | 4 ( គ្រាប់) | 4 ( គ្រាប់) |
| > 70 គ.ក្រ | 5 ( គ្រាប់) | 5 ( គ្រាប់) |
| កំរិតជាតិថ្នាំ/គ.ក្រ ១ថ្ងៃ | R = 10ម.ក្រ, H = 5ម.ក្រ, Z = 25ម.ក្រ, E = 15ម.ក្រ | |

ចំណាំ: RHZE : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ + ពីរ៉ាស៊ីណាមីដ + អេតំប៊ុយតុល, RH : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ, ម.ក្រ : មីលីក្រាម
ម.ក្រ : មីលីក្រាម, គ.ក្រ : គីឡូក្រាម

## គ. រូបមន្តព្យាបាលជំងឺរបេងសំរាប់កុមារ

ការព្យាបាលជំងឺរបេងកុមារ ក៏មានពីរតំណាក់កាលដូចមនុស្សពេញវ័យដែរ គឺដំណាក់កាលព្យាបាលដំបូង និងដំណាក់កាលព្យាបាលបន្ត ។

### រូបមន្តប្រភេទទី ១ : 2RHZE / 4RH

រូបមន្តប្រភេទទី ១ នេះ គឺសំរាប់ព្យាបាលកុមារដែលមានជំងឺរបេងករណីថ្មីនៃ :

- ជំងឺរបេងសួតវិជ្ជមានបេកា
- ជំងឺរបេងសួតអវិជ្ជមានបេកា សណ្ឋានធ្ងន់ធ្ងរ ( មានដំបៅសួតរាលដាល )
- ជំងឺរបេងក្រៅសួត សណ្ឋានធ្ងន់ធ្ងរ
- ជំងឺរបេង/អេដស៍

*** ដំណាក់កាលព្យាបាលដំបូង:** មានរយៈពេល ២ ខែ (1)

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ៤ មុខ ជារៀងរាល់ព្រឹក រយៈពេល ២ ខែ នៅចំពោះមុខបុគ្គលិកសុខាភិបាល ឬចំពោះមុខអ្នកដែលបានបណ្តុះបណ្តាល ( ហៅថា ដូតស៍ ) ។

ថ្នាំទាំង ៤ មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន ថ្នាំអ៊ីសូនីយ៉ាស៊ីដ ថ្នាំពីរ៉ាស៊ីណាមីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំ មួយគ្រាប់) និងថ្នាំអេតំប៊ុយតុល ។

(1) *ក្នុងករណី ( របេងសួតវិជ្ជមានបេកា ) នៅចុងខែទី ២ នៃការព្យាបាល ការពិនិត្យកំហាក ឃើញនៅតែវិជ្ជមានបេកា នោះត្រូវបន្តការព្យាបាលវគ្គដំបូង ១ ខែទៀត។ ចំពោះករណីនេះ ដំណាក់កាលព្យាបាលបន្តនៅតែ ៤ ខែដដែល ហើយរយៈពេលនៃការព្យាបាលសរុបគឺ ៧ ខែ ។*

*** ដំណាក់កាលព្យាបាលបន្ត:** មានរយៈពេល ៤ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ២ មុខ ជារៀងរាល់ព្រឹកគ្រប់រយៈពេល ៤ ខែ។

ថ្នាំទាំង ២ មុខនោះ គឺថ្នាំ រីហ្វាំពីស៊ីន និងថ្នាំអ៊ីសូនីយ៉ាស៊ីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់) ។

ចំពោះកំរិតថ្នាំឬចំនួនគ្រាប់ថ្នាំដែលត្រូវប្រើ សូមអានតារាងនៅទំព័របន្ទាប់ ។

## រូបមន្តប្រភេទទី១: 2RHZE/ 4RH

### ចំពោះកុមារ អាយុក្រោម១៥ឆ្នាំ ដោយរូបមន្តប្រភេទទី១

| ទម្ងន់មុនពេលព្យាបាល (គ.ក្រ) | ដំណាក់កាលដំបូង: រយៈពេល២ខែ | | | | ដំណាក់កាលបន្ត រយៈពេល៤ខែ | |
|---|---|---|---|---|---|---|
| | **RHZ** 60/30/150 | **RH** 60/30 | **H** 100 | **E** 100 | **RH** 60/30 | **H** 100 |
| <=7 | 1 គ្រាប់ | 1 គ្រាប់ | | 1 គ្រាប់ | 2 គ្រាប់ | |
| 8-10 | 2 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | 3 គ្រាប់ | |
| 11-13 | 3 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | 4 គ្រាប់ | |
| 14-15 | 3 គ្រាប់ | 2 គ្រាប់ | | 3 គ្រាប់ | 5 គ្រាប់ | |
| 16-20 | 4 គ្រាប់ | 1 គ្រាប់ | 1 គ្រាប់ | 4 គ្រាប់ | 5 គ្រាប់ | 1 គ្រាប់ |
| 21-25 | 5 គ្រាប់ | 2 គ្រាប់ | 1 គ្រាប់ | 5 គ្រាប់ | 7 គ្រាប់ | 1 គ្រាប់ |
| 26-29 | 6 គ្រាប់ | 3 គ្រាប់ | | 6 គ្រាប់ | 9 គ្រាប់ | |
| **កំរិតជាតិថ្នាំ/គ.ក្រ .១ថ្ងៃ** | R=15mg (10-20), H=10mg (10-15) , Z=35mg (30-40), E=20mg (15-25) | | | | | |

**ចំណាំ:** RHZ : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ + ពីរ៉ាស៊ីណាមីដ RH : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ, E: អេតំប៊ុយតុល,

H : អ៊ីសូនីញ៉ាស៊ីដ

# រូបមន្តព្យាបាលកុមារដែលមានជំងឺរបេងស្រោមខួរ ឬរបេងសន្លាក់ឆ្អឹង :
# 2RHZE / 10 RH

នៅក្នុងរូបមន្តនេះ តាមអនុសាស្ត្រនីរបស់អង្គការសុខភាពពិភពលោក (Rapid Advice) តំរូវអោយកម្មវិធីជាតិកំចាត់រោគរបេង ធ្វើការព្យាបាលកុមារដែលមានៈ

- របេងស្រោមខួរក្បាល
- របេង មីលីយែរ
- របេង សន្លាក់ឆ្អឹង

មានរយៈពេល ១២ ខែ ដូចបានអធិប្បាយខាងក្រោមនេះ ។

* **ដំណាក់កាលព្យាបាលដំបូងៈ** មានរយៈពេល ២ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ៤ មុខ ជារៀងរាល់ព្រឹក រយៈពេល ២ ខែ នៅចំពោះមុខបុគ្គលិកសុខាភិបាល ឬចំពោះមុខអ្នកដែលបានបណ្តុះបណ្តាល ( ហៅថា ដូតស៍) ។
ថ្នាំទាំង ៤ មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន អ៊ីសូនីយ៉ាស៊ីដ ថ្នាំពីរ៉ាស៊ីណាមីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់) និងថ្នាំអេតំប៊ុយតុល ។

* **ដំណាក់កាលព្យាបាលបន្តៈ** មានរយៈពេល ១០ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ២ មុខ ជារៀងរាល់ព្រឹកគ្រប់រយៈពេល ១០ ខែ ។
ថ្នាំទាំង ២ មុខនោះ គឺថ្នាំ រីហ្វាំពីស៊ីន និងអ៊ីសូនីយ៉ាស៊ីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់) ។

ចំពោះកំរិតថ្នាំ ឬចំនួនគ្រាប់ថ្នាំដែលត្រូវប្រើ សូមអានតារាងនៅទំព័របន្ទាប់ ។

# រូបមន្តប្រភេទទី១: 2RHZE/ 10 RH

## សំរាប់ប្រើចំពោះកុមារ អាយុក្រោម១៥ឆ្នាំ

| ទម្ងន់មុនពេលព្យាបាល (គ.ក្រ) | ដំណាក់កាលដំបូង: រយៈពេល២ខែ | | | | ដំណាក់កាលបន្ត រយៈពេល ១០ខែ | |
|---|---|---|---|---|---|---|
| | **RHZ** 60/30/150 | **RH** 60/30 | **H** 100 | **E** 100 | **RH** 60/30 | **H** 100 |
| <=7 | 1 គ្រាប់ | 1 គ្រាប់ | | 1 គ្រាប់ | 2 គ្រាប់ | |
| 8-10 | 2 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | 3 គ្រាប់ | |
| 11-13 | 3 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | 4 គ្រាប់ | |
| 14-15 | 3 គ្រាប់ | 2 គ្រាប់ | | 3 គ្រាប់ | 5 គ្រាប់ | |
| 16-20 | 4 គ្រាប់ | 1 គ្រាប់ | 1 គ្រាប់ | 4 គ្រាប់ | 5 គ្រាប់ | 1 គ្រាប់ |
| 21-25 | 5 គ្រាប់ | 2 គ្រាប់ | 1 គ្រាប់ | 5 គ្រាប់ | 7 គ្រាប់ | 1 គ្រាប់ |
| 26-29 | 6 គ្រាប់ | 3 គ្រាប់ | | 6 គ្រាប់ | 9 គ្រាប់ | |
| **កំរិតជាតិថ្នាំ/គ.ក្រ.១ថ្ងៃ** | R=15mg (10-20), H=10mg (10-15) , Z=35mg (30-40), E=20mg (15-25) | | | | | |

**ចំណាំ:** RHZ : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ + ពីរ៉ាស៊ីណាមីដ RH : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ, E: អេតំប៊ុយតុល

## របបព្យាបាលប្រភេទទី ២ : 2RHZES/ 1RHZE / 5 RHE

របបព្យាបាលប្រភេទទី ២ នេះ មានរយៈពេលសរុប ៨ ខែ និងសំរាប់ព្យាបាលជំងឺរបេងដូចខាងក្រោម:

- ករណីរបេងលាប់
- ករណីរបេងបរាជ័យ
- ករណីរបេងត្រឡប់មកវិញក្រោយបោះបង់ការព្យាបាល
- ករណីផ្សេងៗ

*** ដំណាក់កាលព្យាបាលដំបូង:** មានរយៈពេល ៣ ខែ (1) ដោយចែកចេញជាពីរផ្នែកទៀត :

-ផ្នែកទី ១: មានរយៈពេល ២ ខែ ដោយប្រើថ្នាំ ៥ មុខ ។ នៅក្នុងរយៈពេល ២ ខែនេះ អ្នកជំងឺត្រូវលេប និង ចាក់ថ្នាំ ជារៀងរាល់ព្រឹក នៅចំពោះមុខបុគ្គលិកសុខាភិបាល ។ ថ្នាំទាំង៥មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន ថ្នាំអ៊ីសូនីយ៉ាស៊ីដ និងថ្នាំពីរ៉ាស៊ីណាមីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) ថ្នាំអេតាំប៊ុតុល និងថ្នាំស្ត្រេបតូម៉ីស៊ីន ។

-ផ្នែកទី២: មានរយៈពេល ១ ខែ ដោយប្រើថ្នាំ ៤ មុខ ។ នៅក្នុងរយៈពេល ១ ខែនេះ អ្នកជំងឺត្រូវលេបថ្នាំ ជារៀងរាល់ព្រឹក នៅចំពោះមុខបុគ្គលិកសុខាភិបាល ឬចំពោះមុខអ្នកដែលបានបណ្តុះបណ្តាល ។ ថ្នាំទាំង ៤ មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន ថ្នាំអ៊ីសូនីយ៉ាស៊ីដ និងថ្នាំពីរ៉ាស៊ីណាមីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) និងថ្នាំអេតំប៊ុយតុល ។

(1) *ក្នុងករណី នៅចុងខែទី ៣ នៃការព្យាបាល ការពិនិត្យកំហាកឃើញនៅតែវិជ្ជមានបេកា នោះត្រូវបន្តការព្យាបាលវគ្គដំបូង ១ ខែទៀត ( ផ្នែកទី២ ) ។ ចំពោះករណីនេះ ដំណាក់កាល ព្យាបាលបន្ត នៅសល់តែ ៤ ខែប៉ុណ្ណោះ ។*

*** ដំណាក់កាលព្យាបាលបន្ត:** មានរយៈពេល ៥ ខែ

នៅក្នុងដំណាក់កាលនេះ អ្នកជំងឺត្រូវលេបថ្នាំ ៣ មុខ ជារៀងរាល់ព្រឹកនៅចំពោះមុខ សមាជិកសហគមន៍ ឬគ្រួសារអ្នកដែលបានទទួលការណែនាំ។ ការផ្តល់ថ្នាំដល់អ្នកជំងឺ ត្រូវធ្វើឡើងយ៉ាងតិចរាល់ពីរអាទិត្យ ជាមួយនឹងដំបូន្មានទៀងទាត់របស់បុគ្គលិកសុខាភិបាល ។ ថ្នាំទាំង ៣ មុខនោះ គឺ ថ្នាំរីហ្វាំពីស៊ីន និងអ៊ីសូនីយ៉ាស៊ីដ ( ផ្សំចូលគ្នាជាគ្រាប់ថ្នាំមួយគ្រាប់ ) និងថ្នាំអេតំប៊ុយតុល ។

ចំពោះកំរិតថ្នាំ ឬចំនួនគ្រាប់ថ្នាំដែលត្រូវប្រើ សូមអានតារាងនៅទំព័របន្ទាប់ ។

## រូបមន្តប្រភេទទី២: 2RHZES/1 RHZE/ 5 RHE

### សំរាប់ប្រើចំពោះកុមារ អាយុក្រោម១៥ឆ្នាំ

| ទម្ងន់មុនពេលព្យាបាល (គ.ក្រ) | ដំណាក់កាលដំបូង: រយៈពេល៣ខែ | | | | | | | | | ដំណាក់កាលបន្ត រយៈពេល៥ខែ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែទី១ និង ខែទី២ | | | | | ខែទី៣ | | | | | | |
| | **RHZ** 60/30/150 | **RH** 60/30 | **H** 100 | **E** 100 | **S** 1g | **RHZ** 60/30/150 | **RH** 60/30 | **H** 100 | **E** 100 | **RH** 60/30 | **H** 100 | **E** 100 |
| <=7 | 1 គ្រាប់ | 1 គ្រាប់ | | 1 គ្រាប់ | 100 mg | 1 គ្រាប់ | 1 គ្រាប់ | | 1 គ្រាប់ | 2 គ្រាប់ | | 1 គ្រាប់ |
| 8-10 | 2 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | 150mg | 2 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | 3 គ្រាប់ | | 2 គ្រាប់ |
| 11-13 | 3 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | 200mg | 3 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | 4 គ្រាប់ | | 2 គ្រាប់ |
| 14-15 | 3 គ្រាប់ | 2 គ្រាប់ | | 3 គ្រាប់ | 250mg | 3 គ្រាប់ | 2 គ្រាប់ | | 3 គ្រាប់ | 5 គ្រាប់ | | 3 គ្រាប់ |
| 16-20 | 4 គ្រាប់ | 1 គ្រាប់ | 1 គ្រាប់ | 4 គ្រាប់ | 300mg | 4 គ្រាប់ | 1 គ្រាប់ | 1 គ្រាប់ | 4 គ្រាប់ | 5 គ្រាប់ | 1 គ្រាប់ | 4 គ្រាប់ |
| 21-25 | 5 គ្រាប់ | 2 គ្រាប់ | 1 គ្រាប់ | 5 គ្រាប់ | 350mg | 5 គ្រាប់ | 2 គ្រាប់ | 1 គ្រាប់ | 5 គ្រាប់ | 7 គ្រាប់ | 1 គ្រាប់ | 5 គ្រាប់ |
| 26-29 | 6 គ្រាប់ | 3 គ្រាប់ | | 6 គ្រាប់ | 400mg | 6 គ្រាប់ | 3 គ្រាប់ | | 6 គ្រាប់ | 9 គ្រាប់ | | 6 គ្រាប់ |
| កំរិតជាតិថ្នាំ/គ.ក្រ .១ថ្ងៃ | R=15mg (10-20), H=10mg (10-15) , Z=35mg (30-40), E=20mg (15-25), **S**=15 mg | | | | | | | | | | | |

**ចំណាំ:** RHZ : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ + ពីរ៉ាស៊ីណាមីដ RH : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ, E: អេតំប៊ុយតុល S: ស្ត្រេបតូមីស៊ីន

# រូបមន្តប្រភេទទី ៣ : 2RHZ / 4RH

រូបមន្តប្រភេទទី ៣ នេះគឺសំរាប់ព្យាបាលកុមារដែលមានជំងឺរបេងករណីថ្មី :

- របេងសួតអវិជ្ជមានបេកា សណ្ឋានមិនធ្ងន់ធ្ងរ ( មិនមានដំបៅសួតរាលដាល )
- របេងក្រៅសួត សណ្ឋានមិនធ្ងន់ធ្ងរ ( កូនកណ្តុរ, ស្រោមសួតតែមួយខាង ។

*** ដំណាក់កាលព្យាបាលដំបូង:** មានរយៈពេល ២ ខែ

នៅក្នុងដំណាក់កាលនេះ កុមារមានជំងឺត្រូវលេបថ្នាំ ៣ មុខ ជារៀងរាល់ព្រឹក រយៈពេល ២ ខែ ។ ថ្នាំទាំង៣មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន, អ៊ីសូនីយ៉ាស៊ីដ និងថ្នាំពីរ៉ាស៊ីណាមីដ ( ថ្នាំផ្សំបញ្ចូលគ្នាជាគ្រាប់តែមួយ) ។

*** ដំណាក់កាលព្យាបាលបន្ត:** មានរយៈពេល ៤ ខែ

នៅក្នុងដំណាក់កាលនេះ កុមារមានជំងឺត្រូវលេបថ្នាំ ២ មុខ ជារៀងរាល់ព្រឹក រយៈពេល ៤ ខែ ។ ថ្នាំទាំង ២ មុខនោះ គឺថ្នាំរីហ្វាំពីស៊ីន និងអ៊ីសូនីយ៉ាស៊ីដ ( ថ្នាំផ្សំបញ្ចូលគ្នាជាគ្រាប់តែមួយ) ។

ចំពោះកំរិតថ្នាំ ឬចំនួនគ្រាប់ថ្នាំដែលត្រូវប្រើ សូមអានតារាងនៅទំព័របន្ទាប់ ។

សំគាល់: ត្រូវតាមដានយ៉ាងម៉ត់ចត់ នូវការលេបថ្នាំរបស់កុមារ ។ ឯការផ្តល់ថ្នាំ ត្រូវធ្វើឡើងរាល់សប្តាហ៍ ឬ ញឹកជាងនេះ ។

# រូបមន្តប្រភេទទី៣: 2RHZ/ 4RH

## សំរាប់ប្រើចំពោះកុមារ អាយុក្រោម១៥ឆ្នាំ

| ទម្ងន់មុនពេលព្យាបាល (គ.ក្រ) | ដំណាក់កាលដំបូង: រយៈពេល២ខែ | | | ដំណាក់កាលបន្ត: រយៈពេល៤ខែ | |
|---|---|---|---|---|---|
| | **RHZ** 60/30/150 | **RH** 60/30 | **H** 100 | **RH** 60/30 | **H** 100 |
| <=7 | 1 គ្រាប់ | 1 គ្រាប់ | | 2 គ្រាប់ | |
| 8-10 | 2 គ្រាប់ | 1 គ្រាប់ | | 3 គ្រាប់ | |
| 11-13 | 3 គ្រាប់ | 1 គ្រាប់ | | 4 គ្រាប់ | |
| 14-15 | 3 គ្រាប់ | 2 គ្រាប់ | | 5 គ្រាប់ | |
| 16-20 | 4 គ្រាប់ | 1 គ្រាប់ | 1 គ្រាប់ | 5 គ្រាប់ | 1 គ្រាប់ |
| 21-25 | 5 គ្រាប់ | 2 គ្រាប់ | 1 គ្រាប់ | 7 គ្រាប់ | 1 គ្រាប់ |
| 26-29 | 6 គ្រាប់ | 3 គ្រាប់ | | 9 គ្រាប់ | |
| **កំរិតជាតិថ្នាំ/គ.ក្រ .១ថ្ងៃ** | R=15mg (10-20), H=10mg (10-15) , Z=35mg (30-40) | | | | |

**ចំណាំ:** RHZ : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ + ពីរ៉ាស៊ីណាមីដ RH : រីហ្វាំពីស៊ីន + អ៊ីសូនីញ៉ាស៊ីដ,

E: អេតំប៊ុយតុល

# ឃ_និយមន័យ

**របេង** : គឺជាជំងឺឆ្លង ដែលបណ្តាលមកពីមេរោគប្រភេទបាក់តេរី មានឈ្មោះថា មីកូបាក់តេរីយូម ទុយប៊ែគុយឡូស៊ីស ឬបាស៊ីដឺកុក ឬបេកា ។

**ចំណាត់ថ្នាក់តាមទីកន្លែង និង បាក់តេរីសាស្ត្រ** :

**- របេងសួតវិជ្ជមានបេកា** :

ក-គឺអ្នកជំងឺមានវិជ្ជមានបេកាយ៉ាងហោចណាស់ ២ ដង តាមរយៈការពិនិត្យកំហាកដោយមីក្រូទស្សន៍ ។

ខ-ឬវិជ្ជមានបេកា ១ដង រួមផ្សំនឹងសញ្ញារូបថតសួតគួរឱ្យចាប់អារម្មណ៍ ថាមានរបេងសកម្ម ព្រមទាំងមានការសំរេចចិត្តពីគ្រូពេទ្យ ។

គ-ឬវិជ្ជមានបេកា ១ ដង រួមផ្សំនឹងការបណ្តុះមេរោគឃើញ បេកាវិជ្ជមាន ។

**-របេងសួតអវិជ្ជមានបេកា** : គឺអ្នកជំងឺដែលមាន រូបថតសួតគួរឱ្យចាប់អារម្មណ៍ថា មានរបេងសកម្ម កំហាកត្រូវបានពិនិត្យឃើញអវិជ្ជមានបេកាយ៉ាងហោចណាស់ ៦ដង និងព្យាបាលថ្នាំមេរោគ ឃាតក្រៅពីថ្នាំ របេងមិនធូរស្រាល ព្រមទាំងមានការសំរេចចិត្តពីគ្រូពេទ្យ ។

**- របេងក្រៅសួត** : គឺជារបេងនៃសរីរាង្គដទៃទៀតក្រៅពីសួត ដូចជា : កូនកណ្តុរនៅអ៊ឹលស្រោមសួត កូនកណ្តុរនៅត្រង់ក ( ម្រេញ) របេងស្រោមខួរក្បាល ឆ្អឹង សន្លាក់ ។ល ។ រោគវិនិច្ឆ័យត្រូវបានធ្វើឡើងដោយការបណ្តុះមេរោគឃើញវិជ្ជមាន ឬពិសោធន៍ជាលិកាសាស្ត្រអមគ្លីនិក ជាក់ស្តែង ឬសញ្ញាគ្លីនិក ថាមានរបេងសកម្ម និងមានការសំរេចចិត្តពីគ្រូពេទ្យ ។

## ប្រភេទអ្នកជំងឺក្នុងការចុះបញ្ជីរោគវិនិច្ឆ័យៈ

**-អ្នកជំងឺថ្មី :** គឺអ្នកជំងឺមិនដែលព្យាបាលរបេងសោះពីមុនមក ឬ ក៏ព្យាបាលរបេងដែរតែតិចជាង១ខែ ។

**-ជំងឺលាប់ :** គឺអ្នកជំងឺដែលបានព្យាបាលរបេងពីមុនមក ហើយត្រូវបានចាត់ទុកថាជាសះស្បើយ ឬបញ្ចប់ ការព្យាបាល ប៉ុន្តែឥឡូវនេះគាត់មានកំហាកវិជ្ជមានបេកា ។

**-ជំងឺបរាជ័យ :** គឺជាអ្នកជំងឺដែលចាប់ផ្តើមព្យាបាលជាថ្មី ព្រោះគាត់មានវិជ្ជមានបេកានៅខែទី៥ ឬនៅពេលណាមួយ ចន្លោះខែទី ៥ ទៅដល់ពេលបញ្ចប់ការព្យាបាល ។

**-ត្រឡប់មកវិញក្រោយបោះបង់ :** គឺអ្នកជំងឺរបេងដែលបានព្យាបាលយ៉ាងតិច ១ ខែ និងវិលមកវិញ មានវិជ្ជមានបេកា បន្ទាប់ពីមិនបានទទួលការព្យាបាលយ៉ាងតិច ២ ខែ ។

- **បញ្ជូនចូលៈ** ជាអ្នកជំងឺដែលបានបញ្ជូនមកពីមណ្ឌលព្យាបាលនៃស្រុកប្រតិបត្តិមួយ( ដែលមានការចុះបញ្ជី) មកបន្តការព្យាបាលនៅមណ្ឌលព្យាបាលនៃស្រុកប្រតិបត្តិមួយទៀត ។

**-ផ្សេងៗៈ** គ្រប់ករណីដែលមិនមានចែងក្នុងប្រភេទករណីទាំង ៥ ខាងលើ ករណីនេះរាប់បញ្ចូលទាំងករណីរ៉ាំរ៉ៃ អ្នកជំងឺដែលមានបេកាវិជ្ជមាន នៅពេលចុងបញ្ចប់នៃការព្យាបាលឡើងវិញ ។

***កំណត់សំគាល់*** : ទោះបីករណីរបេងសួតបេកាអវិជ្ជមាន និងរបេងក្រៅសួតក៏អាចមានលាប់ ឬបរាជ័យ ឬករណីរ៉ាំរ៉ៃដែរ ប៉ុន្តែជាករណីដ៏កំរបំផុតដែលត្រូវអះអាងដោយការរកឃើញមេរោគ ។

## លទ្ធផលនៃការព្យាបាលរបេងសួត វិជ្ជមានបេកា:

**-ជាសះស្បើយ :** ជាអ្នកជំងឺដែលមានកំហាកអវិជ្ជមានបេកានៅខែទី ៥ និងនៅខែចុងក្រោយនៃការព្យាបាល (ពាក់កណ្តាលខែទី ៦ ចំពោះរូបមន្តទី ១ និងដើមខែទី ៨ ចំពោះរូបមន្តទី ២) ។

**-បញ្ចប់ការព្យាបាល :** ជាអ្នកជំងឺដែលបានបញ្ចប់ការព្យាបាល ប៉ុន្តែមិនបំពេញបានលក្ខណៈវិនិច្ឆ័យបានថា "ជាសះស្បើយ" ឬ "បរាជ័យ" ។

**-បរាជ័យ :** គឺជាអ្នកជំងឺដែលមានវិជ្ជមានបេកា នៅខែទី ៥ ឬ នៅពេលណាមួយចន្លោះដំណាច់ខែទី ៥ ទៅដល់ពេលបញ្ចប់ការព្យាបាល ។

**-ស្លាប់ :** អ្នកជំងឺស្លាប់ដោយសារមូលហេតុណាក៏ដោយ ក្នុងកំឡុងពេលព្យាបាល ។

**-លះបង់ :** អ្នកជំងឺដែលមិនបានទទួលការពារព្យាបាល រយៈពេលយ៉ាងតិច ២ខែជាប់គ្នា មុនពេលបញ្ឈប់ការព្យាបាល ។

**-បញ្ជូនចេញ :** ជាអ្នកជំងឺដែលត្រូវបញ្ជូនទៅមណ្ឌលព្យាបាល នៅក្នុងស្រុកប្រតិបត្តិមួយទៀត (ដែលមានផ្នែក ចុះបញ្ជីកត់ត្រា និងរាយការណ៍) ហើយគេពុំបានដឹងលទ្ធផល នៃការការព្យាបាលរបស់គាត់ ។

**-ព្យាបាលជោគជ័យ :** ជាការបូករួមគ្នានៃអ្នកជាសះស្បើយ និងអ្នកបញ្ចប់ការព្យាបាល ។

***កំណត់សំគាល់:*** ចំពោះប្រទេសដែលមានលទ្ធភាព បណ្តុះមេរោគគ្រប់ទីកន្លែង អ្នកជំងឺអាចធ្វើចំណាត់ថ្នាក់ថា ជាសះស្បើយ ឬ បរាជ័យ ដោយផ្អែកលើលទ្ធផលនៃការបណ្តុះមេរោគ ។

Printing Supported by

**The Global Fund to Fight AIDS, Tuberculosis and Malaria**

(GFATM)